# ប្រវត្តិសង្ខេបអ្នកការពារសិទ្ធិមនុស្ស ទាំង ១០ រូប

អ្នកការពារសិទ្ធិមនុស្សទាំង ១០ រូប ដែលមានប្រវត្តិរូបសង្ខេបដូចខាងក្រោមនេះ សុទ្ធតែជាថ្នាក់ដឹកនាំ និងសមាជិករបស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU) ។ សមាជិកសហជីពទាំងនេះ ជាអតីតបុគ្គលិកនៃក្រុមហ៊ុនណាហ្គាវើលដ៍ ដែលជាក្រុមហ៊ុនកាស៊ីណូរកប្រាក់ចំណេញបានយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ក្រុមហ៊ុននេះ មានម្ចាស់ជាជនជាតិម៉ាឡេស៊ី និងមានអាជ្ញាប័ណ្ណប្រតិបត្តិការផ្តាច់មុខក្នុងរាជធានីភ្នំពេញ ។ អ្នកទាំង ១០ រូប ដែលរួមមានទាំងបុរស និងស្ត្រី កំពុងជាប់ឃុំក្នុងពន្ធនាគារ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) មណ្ឌលអប់រំកែប្រែទី២ (ម២) និងពន្ធនាគាររាជធានីភ្នំពេញ (ប៉េស៊ី) ។

សូមអានប្រវត្តិរបស់អ្នកទាំង ១០ រូប ខាងក្រោមនេះ ៖




សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើលធ្វើកូដកម្មនៅថ្ងៃ២៤ ខែធ្នូ ឆ្នាំ២០២១



ឈឹម ស៊ីថរ(ឆ្វេង) ម្តាយ(កណ្តាល) ប្អូន(ស្តាំ)

# ឈឹម ស៊ីថរ

កញ្ញា ឈឹម ស៊ីថរ មានអាយុ ៣៤ឆ្នាំ ។ នាងមកពីគ្រួសារមួយដែលមានសមាជិកច្រើន ។ នាងជាកូនទីពីរ ក្នុងចំណោមបងប្អូន ៦ នាក់ រួមមានបងប្អូនប្រុស បួននាក់ និងបងប្អូនស្រីម្នាក់ ។ មុនពេលនាងត្រូវបានគេចាប់ខ្លួន នាងក៏ជាអ្នកដែលជួយផ្គត់ផ្គង់ជីវភាពដល់ពូរបស់នាង អាយុ ៥៧ឆ្នាំ ដែលកំពុងមានជំងឺមហារីកគ្រាប់ឈាម ម្តាយចាស់ជរា អាយុ ៦៥ ឆ្នាំ និងប្អូនប្រុសអាយុ ៣៣ ឆ្នាំ ។ ស៊ីថរ បានបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា ។

ស៊ីថរ បានធ្វើការនៅក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ តាំងពីឆ្នាំ ២០០៧ និងបានក្លាយជាប្រធានសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ នៅឆ្នាំ ២០១០ ។ ក្នុងឆ្នាំ ២០១៣ នាងត្រូវបានក្រុមហ៊ុនណាហ្គាវើលដ៍ ប្តឹងពីការធ្វើកូដកម្មខុសច្បាប់ ។ ក្រុមហ៊ុនបានដាក់ពាក្យបណ្តឹង និងទារសំណងចំនួនមួយលានដុល្លារពីនាង ប៉ុន្តែពាក្យបណ្តឹងនោះនៅបន្តទុកចោលរហូតដល់ពេលនេះ ។ ក្នុងឆ្នាំដដែល ស៊ីថរ ក៏ត្រូវគេចាប់ខ្លួន និងសួរនាំពីការចូលជាសហជីពរបស់នាង ។ នៅខែកញ្ញា ឆ្នាំ ២០១៩ នាងត្រូវបានក្រុមហ៊ុនណាហ្គាវើលដ៍ផ្អាកការងារដោយមានប្រាក់ខែ ខណៈពេលនាងកំពុងធ្វើយុទ្ធនាការទាមទារប្រាក់ខែសមរម្យដល់កម្មកររាប់ពាន់នាក់ ។ ក្រោយមកនាងត្រូវបានក្រុមហ៊ុនឱ្យចូលធ្វើការវិញ ក្រោយពេលដែលមានកូដកម្មពីកម្មករទាំងនោះ ។ ជាចុងក្រោយ នាងត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារក្នុងខែមេសា ឆ្នាំ ២០២១ រួមជាមួយថ្នាក់ដឹកនាំសហជីពទាំងអស់ ។

ស៊ីថរ ត្រូវបានចោទប្រកាន់ នៅថ្ងៃទី ៣ ខែមករា ២០២២ និងត្រូវបានចាប់ខ្លួនយ៉ាងហិង្សានៅថ្ងៃបន្ទាប់ នៅពេលដែលនាងព្យាយាមទៅចូលរួមជាមួយនឹងសមាជិកសហជីពរបស់នាងដែលកំពុងធ្វើកូដកម្មដោយអហិង្សា ។



ឈឹម សុខន(ស្ដាំ) ប្អូន (ឆ្វេង)

# ឈឹម សុខន

អ្នកស្រី ឈឹម សុខន មានអាយុ ៤០ ឆ្នាំ ។ អ្នកស្រីជួយផ្គត់ផ្គង់ជីវភាពដល់ឪពុកដែលចាស់ជរា អាយុ ៦៦ ឆ្នាំ ហើយកំពុងមានជំងឺទឹកនោមផ្អែម និងម្ដាយ អាយុ ៦៨ ឆ្នាំ ដែលជាសន្តិសុខឯកជននៅខេត្តសៀមរាប ។ អ្នកស្រីបានចំណាយពេល១៩ឆ្នាំធ្វើការឱ្យក្រុមហ៊ុនណាហ្គាវើលដ៍ និងបានជួយរៀបចំកិច្ចការងារនៅក្នុងសហជីព ។ អ្នកស្រីមានតួនាទីការងារជាលេខារបស់សហជីព ។ អ្នកស្រីចង់ការពាររាល់បុគ្គលិកទាំងអស់នៅក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ ។ អ្នកស្រី សុខន ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ២០២១ នៅការិយាល័យសហជីព ។ ខណៈដែលអ្នកស្រីកំពុងជាប់ឃុំក្នុងពន្ធនាគារ អ្នកស្រីពិតជានឹកនាជាខ្លាំងដល់ក្រុមគ្រួសារ មិត្តភក្ដិ និងការងាររបស់អ្នកស្រី ។



ឃ្លាំង សុបិន្ត និងស្វាមី

# ឃ្លាំង សុបិន្ត

អ្នកស្រី ឃ្លាំង សុបិន្ត មានអាយុ ៤១ ឆ្នាំ ។ អ្នកស្រី ទើបតែបានរៀបការថ្មីៗនេះ កាលពីខែ មករា ឆ្នាំ២០២១ ប៉ុន្តែឆ្នាំនេះដែលជាខួបអាពាហ៍ពិពាហ៍ ១ឆ្នាំរបស់អ្នកស្រី អ្នកស្រីត្រូវបានគេឃុំខ្លួនក្នុងពន្ធនាគារទៅវិញ ។ អ្នកស្រី ទទួលបន្ទុកចិញ្ចឹម សមាជិកក្នុងគ្រួសារបីនាក់ រួមមានម្ដាយ ស្វាមី និងប្អូនប្រុសម្នាក់របស់អ្នកស្រី ។ អ្នកស្រីសុបិន្តបានធ្វើការនៅក្នុងក្រុមហ៊ុនណាហ្គាវើលដ៍តាំងពីឆ្នាំ ២០០៣ និងបានចូលរួមជាមួយសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ ពេលដែលគាត់ចាប់ផ្តើមធ្វើការងារដំបូងក្នុងកាស៊ីណូមកម្ល៉េះ ។ បច្ចុប្បន្នអ្នកស្រីជាតំណាងកម្មករម្នាក់នៅក្នុងសហជីពនេះ ។ អ្នកស្រីត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ នៅការិយាល័យសហជីព ។ អ្នកស្រីសុបិន្តនឹកក្រុមគ្រួសារ និងមិត្តភក្តិអ្នកស្រីយ៉ាងខ្លាំង ។



ស៊ុន ស្រីពេជ្រ និងម្តាយ

# ស៊ុន ស្រីពេជ្រ

អ្នកនាង ស៊ុន ស្រីពេជ្រ មានអាយុ ៣១ឆ្នាំ ។ អ្នកនាងជាម្តាយទោលដែលត្រូវចិញ្ចឹមកូនប្រុសអាយុ ១១ឆ្នាំម្នាក់ កំពុងរៀននៅថ្នាក់ទី ៦ និងម្តាយចាស់ជរាម្នាក់ អាយុ ៦៦ឆ្នាំ ដែលកំពុងជួយមើលថែកូនប្រុសរបស់អ្នកនាង ។ អ្នកនាងបានលែងលះជាមួយអតីតស្វាមី និងទើបតែភ្ជាប់ពាក្យថ្មីម្តងទៀត ។ អ្នកនាងស្រីពេជ្រ ជាតំណាងកម្មករម្នាក់នៅក្នុងសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ នៅការិយាល័យសហជីព ។



ហៃ សុភាព និងម្ដាយ

# ហៃ សុភាព

អ្នកស្រី ហៃ សុភាព មានអាយុ ៣៥ ឆ្នាំ ។ អ្នកស្រីជាម្ដាយ និងជាស្ត្រីមេម៉ាយដែលកំពុងចិញ្ចឹមសមាជិកក្នុងគ្រួសារបីនាក់ រួមមាន ម្ដាយអាយុ ៦៨ ឆ្នាំ ដែលមានជំងឺរ៉ាំរ៉ៃ កូនស្រីអាយុ ១១ ឆ្នាំដែលកំពុងរៀននៅថ្នាក់ទី ៧ និងប្អូនប្រុស អាយុ ២១ ឆ្នាំដែលជានិស្សិតឆ្នាំទី ៣ នៅសាកលវិទ្យាល័យ ។ អ្នកស្រី សុភាព បានធ្វើការនៅក្រុមហ៊ុនណាហ្គាវើលដ៍ តាំងពីឆ្នាំ ២០០៦មកម្ល៉េះ ។ បន្ទាប់ពីធ្វើការបានមួយឆ្នាំ គាត់ក៏បានចូលរួមក្នុងសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ ក្នុងគោលបំណងជួយដោះស្រាយនូវភាពអយុត្តិធម៌ដែលអ្នកស្រីបានឃើញនៅកន្លែងការងារ ហើយបច្ចុប្បន្នអ្នកស្រីជាតំណាងកម្មករម្នាក់ ។ អ្នកស្រីត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ នៅការិយាល័យសហជីព ខណៈដែលអ្នកស្រីនៅជាបុគ្គលិករបស់ក្រុមហ៊ុននៅឡើយ ។ ទោះបីជាយ៉ាងណាអ្នកស្រីសុភាពបានចូលរួមធ្វើកូដកម្មអហិង្សាដើម្បីស្វែងរកយុត្តិធម៌ សម្រាប់បុគ្គលិកទាំងនោះ ។ អំឡុងពេលដែលអ្នកស្រីជាប់ឃុំឃាំង អ្នកស្រីដេរកាបូបជាច្រើន ។ អ្នកស្រីនឹកដល់ក្រុមគ្រួសាររបស់អ្នកស្រីខ្លាំងណាស់ ។



រី សុវណ្ណឌី និងជីដូន

# រី សុវណ្ណឌី

អ្នកស្រី រី សុវណ្ណឌី មានអាយុ ៤០ ឆ្នាំ ។ អ្នកស្រីរស់នៅជាមួយស្វាមីដែលជាអ្នកបើករ៉ឺម៉កម៉ូតូកង់បី( តុក តុក ) ។ អ្នកស្រីជាអ្នករកប្រាក់ចំណូលធំជាងគេបង្អស់ ក្នុងការជួយផ្គង់ផ្គង់ក្នុងគ្រួសារដែលមាន ម្ដាយចាស់ជរាអាយុ ៦០ឆ្នាំ និងឪពុកអាយុ ៦៥ ឆ្នាំ ដែលកំពុងរស់នៅក្នុងខេត្តកណ្ដាល ក្បែររាជធានីភ្នំពេញ ។ អ្នកស្រីសុវណ្ណឌី គឺជាបងស្រីគេបង្អស់ ក្នុងចំណោមកូនបួននាក់ ។ អ្នកស្រីមានប្អូនប្រុសពីរនាក់ ជាអ្នកលក់បន្លែ និងប្អូនស្រីម្នាក់ ជាបុគ្គលិកក្នុងក្រុមហ៊ុនឯកជនមួយ ។ អ្នកស្រី ជាតំណាងកម្មករក្នុងសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ នៅការិយាល័យសហជីព ។



ទូច សេរីមាស (ស្តាំ) និងដៃគូររបស់គាត់ (ឆ្វេង)

# ទូច សេរីមាស

អ្នកនាង ទូច សេរីមាស មានអាយុ ២៩ ឆ្នាំ ។ អ្នកនាងមានគ្រួសារតូចមួយ ដែលរួមមានដៃគូជីវិតរបស់អ្នកនាងបងប្រុស និងបងស្រីដែលកំពុងធ្វើការនៅក្នុងកាស៊ីណូមួយក្នុងខេត្តព្រះសីហនុ ។ អ្នកនាង គឺជាសមាជិករបស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ នៅពេលដែលអ្នកនាងកំពុងតែចាកចេញពីកន្លែងធ្វើកូដកម្មអហិង្សានៅមុខក្រុមហ៊ុនណាហ្គាវើលដ៍ ។ គិតត្រឹមពេលចាប់ខ្លួនអ្នកនាង សេរីមាស នៅជាបុគ្គលិកបម្រើការងារក្នុងក្រុមហ៊ុនណាហ្គាវើលដ៍នៅឡើយ ហើយអ្នកនាងបានចូលរួមធ្វើកូដកម្មដោយអហិង្សាដើម្បីបង្ហាញសាមគ្គីភាពជាមួយនឹងមិត្តភក្តិនិងបុគ្គលិករួមការងាររបស់អ្នកនាង ។



ជួប ចាន់ណាត និងឪពុក

# ជួប ចាន់ណាត

លោក ជួប ចាន់ណាត មានអាយុ ៤៤ ឆ្នាំ ។ លោកបានភ្ជាប់ពាក្យ និងមានឪពុកដែលមានវ័យជរា អាយុ ៩៦ ឆ្នាំ បងប្អូនស្រី ២នាក់ និងបងប្អូនប្រុស ៧នាក់ ។ គូដណ្តឹងរបស់លោកនៅបន្តធ្វើការងារក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ ហើយអ្នកទាំងពីរធ្លាប់រស់នៅជាមួយគ្នានៅរាជធានីភ្នំពេញ ។ លោកចាន់ណាត ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារអំឡុងពេលក្រុមហ៊ុនបញ្ឈប់កម្មករទ្រង់ទ្រាយធំ កាលពីខែមេសា ឆ្នាំ ២០២១ និងបន្ទាប់ពីបម្រើការងារនៅក្រុមហ៊ុននេះរយៈពេលជិត១០ឆ្នាំ ។ លោកសង្ស័យថា លោកត្រូវបានគេបញ្ឈប់ដោយសារតែភាពសកម្មរបស់លោកក្នុងនាមជាសមាជិកនៃសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ ។លោកជាសមាជិករបស់សហជីព និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២២ នៅពេលដែលលោកកំពុងធ្វើដំណើរតាមរ៉ឺម៉កម៉ូតូកង់បីចាកចេញពីកន្លែងធ្វើតេស្តរកមេរោគកូវីដ-១៩មួយ ។ នៅថ្ងៃដដែលនោះ អាជ្ញាធរបានចាប់បង្ខំឱ្យកូដករជាសមាជិកសហជីពចូលក្នុងឡានក្រុងដឹកទៅមណ្ឌលធ្វើតេស្ត ដើម្បីធ្វើតេស្តយកសំណាករកជំងឺកូវីដ-១៩ ។ លោកចាន់ណាត បានគោរពតាម និងធ្វើតេស្តឃើញអវិជ្ជមាន មុនពេលដែលលោកត្រូវបានចាប់ខ្លួន ។



សេង វណ្ណារិទ្ធ និងភរិយា

# សេង វណ្ណារិទ្ធ

លោក សេង វណ្ណារិទ្ធ មានអាយុ ៤៥ ឆ្នាំ ។ លោកបានរៀបអាពាហ៍ពិពាហ៍ដោយមានកូនពីរនាក់ ដែលកូនប្រុសអាយុ ១៣ឆ្នាំ កំពុងរៀននៅថ្នាក់ទី ៧ និងកូនស្រីអាយុ ១០ ឆ្នាំ កំពុងរៀននៅថ្នាក់ទី ៤ ។ លោកបានចាប់ផ្តើមធ្វើការក្នុងក្រុមហ៊ុនណាហ្គាវើលដ៍តាំងពីឆ្នាំ ១៩៩៧ និងបានចំណាយពេល ២៥ឆ្នាំ ធ្វើការឱ្យក្រុមហ៊ុននេះរហូតដល់លោកមានតួនាទីជាជំនួយការអ្នកគ្រប់គ្រង មុនពេលដែលលោកត្រូវបានបញ្ឈប់ពីការងារក្នុងខែមេសា ឆ្នាំ២០២១ ។ លោកវណ្ណារិទ្ធ ជាសមាជិកសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២២ ពេលដែលលោកធ្វើដំណើរតាមរ៉ឺម៉កម៉ូតូកង់បីដែលកំពុងតែចាកចេញពីកន្លែងធ្វើតេស្តរកកូវីដ-១៩មួយ។ ភរិយារបស់លោក ក៏ធ្វើការនៅក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ផងដែរ ហើយត្រូវបានគេបញ្ឈប់ពីការងារដូចគ្នាកាលពីខែមេសា ឆ្នាំ២០២១ អំឡុងពេលមានការបញ្ឈប់បុគ្គលិកទ្រង់ទ្រាយធំដោយក្រុមហ៊ុនណាហ្គាវើលដ៍ ។

ដោយសារអ្នកទាំងពីរមិនទទួលបានហេតុផលសមស្របនៃការបញ្ឈប់ពីការងារ អ្នកទាំងពីរមានការសង្ស័យថាឈ្មោះរបស់ពួកគេ ត្រូវបានកាត់ចេញ ដោយសារតែភាពសកម្មរបស់អ្នកទាំងពីរនៅក្នុងសហជីព និងដោយសារតែឥទ្ធិពលរបស់លោកវណ្ណារិទ្ធដែលជាជំនួយការអ្នកគ្រប់គ្រងក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ ។ ទាំងលោក វណ្ណារិទ្ធិ និងភរិយា បានចូលរួមធ្វើកូដកម្មអហិង្សារបស់សហជីពនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២១ និងបន្តធ្វើកូដកម្មអហិង្សាជិត២ខែ រហូតដល់អ្នកទាំងពីរត្រូវបានចាប់ខ្លួន ។ ភរិយារបស់វណ្ណារិទ្ធិ ត្រូវបានដោះលែងវិញនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២២ ។




សៅ សម្បត្តិ និងភរិយា

# សៅ សម្បត្តិ

លោក សៅ សម្បត្តិ មានអាយុ ៣១ ឆ្នាំ ។ លោកមានគ្រួសារមួយ និងមានកូនស្រីពីរនាក់ ដែលម្នាក់អាយុ ២ ឆ្នាំ និងម្នាក់ទៀតអាយុ ៤ ឆ្នាំ ។ ភរិយារបស់លោកសម្បត្តិ ក៏ធ្លាប់បានធ្វើការក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ដែរ និងត្រូវបានបញ្ឈប់ពីការងារដូចគ្នាក្នុងខែមេសា ឆ្នាំ២០២១ អំឡុងពេលដែលមានការបញ្ឈប់បុគ្គលិកយ៉ាងច្រើនដោយក្រុមហ៊ុនណាហ្គាវើលដ៍ ។ គូស្វាមីភរិយានេះ ក៏មិនទទួលបាន ហេតុផលសមស្របណាមួយទាក់ទងនឹងការបញ្ឈប់ពីការងារនេះទេ ដែលធ្វើឱ្យអ្នកទាំងពីរមានការសង្ស័យថា ដោយសារតែពួកគេជាសមាជិកនៃសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ ។ ដោយឱកាសការងារក្នុងរាជធានីមានតិច ភរិយារបស់លោកក៏បានផ្លាស់ទៅខេត្តព្រះសីហនុដែលជាកន្លែងធ្វើការងារបច្ចុប្បន្នរបស់អ្នកស្រីដើម្បីផ្គត់ផ្គង់ដល់កូនស្រីនិងគ្រួសារ ខណៈដែលម្ដាយរបស់លោកសម្បត្តិនៅមើលថែកូនៗរបស់អ្នកទាំងពីរ ។ លោកសម្បត្តិ ជាសមាជិកនៃសហជីព និងបានចូលរួមក្នុងសហជីពនេះអស់ពេល ១០ឆ្នាំមកហើយ ។ លោកត្រូវបានចាប់ខ្លួននៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២២ នៅពេលដែលលោកធ្វើដំណើរតាមរ៉ឺម៉ក់ម៉ូតូកង់បីចាកចេញពីកន្លែងធ្វើតេស្តរកកូវីដ-១៩មួយ ។




សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍(LRSU) បានរៀបចំ និងធ្វើកូដកម្ម ដោយសន្តិវិធីក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ក្នុងគោលបំណងអំពាវនាវឱ្យមានការយក សមាជិក និងថ្នាក់ដឹកនាំសហជីពទាំង ៣៦៥ នាក់ ចូលធ្វើការវិញ ក៏ដូចជាទាមទារប្រាក់បំណាច់សមរម្យ តាមច្បាប់ការងារកម្ពុជាសម្រាប់សមាជិកផ្សេងទៀតដែលត្រូវបានក្រុមហ៊ុនណាហ្គាវើលដ៍បញ្ឈប់ពីការងារកាលពី ខែមេសា ឆ្នាំ២០២១ ។

ចាប់ពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ កូដករយ៉ាងតិច ៣៥ នាក់ ត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ពី "បទញុះញង់" តាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ឬ "បទរារាំងដល់ការអនុវត្តវិធានការ" ក្រោមច្បាប់កូវីដ-១៩។ កូដករមួយចំនួនត្រូវបានអាជ្ញាធរដោះលែងឱ្យនៅក្រៅឃុំ ឬក្រោយពីបានធ្វើកិច្ចសន្យាជាមួយនគរបាលរួច។ ទោះជាយ៉ាងនេះក្តីអ្នកការពារសិទ្ធិមនុស្ស ទាំង១០ នាក់ នៅជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅឡើយ ។

ថ្នាក់ដឹកនាំ និងសមាជិកសហជីពចំនួន ៧ រូប ត្រូវបានតុលាការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២២ និងប្រឈមនឹងការជាប់ពន្ធនាគារពី៦ខែ ដល់ ២ ឆ្នាំ ប្រសិនបើ តុលាការរកឃើញថាមានពិរុទ្ធ។ ស្រ្តីអ្នកការពារសិទ្ធិមនុស្សទាំង ៧ នាក់ រួមមាន កញ្ញា ឈឹម ស៊ីថរ អ្នកស្រី ឈឹម សុខន អ្នកស្រី ឃ្លាំង សុបិន្ត អ្នកនាង ស៊ុន ស្រីពេជ្រ អ្នកស្រី ហៃ សុភាព អ្នកស្រី វី សុវណ្ណឌី និងអ្នកនាង ទូច សេរីមាស ដែលកំពុងជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី ២ (ម២) ។

កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២២ សមាជិកសហជីពបីរូបទៀត ត្រូវបានតុលាការចោទប្រកាន់តាមមាត្រា ១១ នៃច្បាប់កូវីដ-១៩ ពីបទរារាំងដល់ការអនុវត្តវិធានការ ។ បទចោទនេះ អាចធ្វើឱ្យអ្នកទាំងបីជាប់ពន្ធនាគារ ចន្លោះពី ៦ខែទៅ ៣ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ១០ លានរៀល និងអាចបន្តជាប់ពន្ធនាគារចន្លោះពី ២ ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់កើនឡើងដល់ ២០ លានរៀល ប្រសិនបើរកឃើញថាបង្កឱ្យមានការឆ្លងរាលដាល ជំងឺកូវីដ-១៩ ឬ"ប៉ះពាល់ធ្ងន់ធ្ងរ" ដល់សុខភាពសាធារណៈ ។ បច្ចុប្បន្ន អ្នកទាំងបីដែលមាន លោក ជួប ចាន់ ណាត លោក សេង វណ្ណារិទ្ធ និងលោកសៅ សម្បត្តិ កំពុងជាប់ឃុំនៅក្នុងពន្ធនាគាររាជធានីភ្នំពេញ (ប៉េស៊ី) ។

ក្នុងពន្ធនាគារទាំងពីរនេះមានលក្ខណៈចង្អៀតណែនខ្លាំង ហើយអ្នកទោសទាំងអស់ស្ថិតក្នុងលក្ខខណ្ឌរស់នៅ យ៉ាងអាក្រក់ ។ ឧទាហរណ៍ បច្ចុប្បន្នមណ្ឌលអប់រំកែប្រែទី ២ កំពុងដាក់អ្នកទោសដល់ទៅ ១៦១ % នៃ សមត្ថភាពស្តង់ដារដែលពន្ធនាគារអាចដាក់បាន ។

សិទ្ធិធ្វើកូដកម្មដោយអហិង្សា មានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ការងារ និងច្បាប់ស្តីពីសហជីព ។ នគរបាល បែរជាព្យាយាមលើកឡើងថាកូដករ ដែលត្រូវបានចាប់ខ្លួនទាំងនោះ ធ្វើកូដកម្មដោយខុសច្បាប់ និងប៉ះពាល់ ដល់សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ហើយថាការចាប់ខ្លួននេះត្រូវបានធ្វើឡើងបន្ទាប់ពីការ ចេញផ្សាយនូវការព្រមានជាច្រើនលើកច្រើនសារដើម្បីបញ្ឈប់កូដកម្មនោះ ៕